# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១៤៤ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរ ដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស ដូចខាងក្រោម៖

១-លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ប្រធាន

| | | | |
|---|---|---|---|
| ២-ឯកឧត្តម | **អ៊ុំ ម៉ារ៉ា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៣-ឯកឧត្តម | **ប្រាក់ សុវណ្ណារ៉ា** | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ៤-ឯកឧត្តម | **សៀង ឈុនទ្រី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥-ឯកឧត្តមបណ្ឌិត | **ឈន សុភាព** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦-ឯកឧត្តម | **ប៉ាក់ សុខុម** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៧-ឯកឧត្តម | **មុខ សុវត្ថិ** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក។ |

**ប្រការ២.-**

គណៈកម្មាធិការអន្តរក្រសួងដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យនិងសម្រេចលើសំណើសុំយកវត្ថុសិល្បៈបុរាណខ្មែរទៅតាំងពិព័រណ៍នៅបរទេស
- សម្របសម្រួលនិងទំនាក់ទំនងជាមួយភាគីបរទេស និងក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងដំណើរការរៀបចំតាំងពិព័រណ៍វត្ថុសិល្បៈបុរាណខ្មែរនៅបរទេស
- ពិនិត្យនិងសម្រេចលើកិច្ចព្រមព្រៀង កិច្ចសន្យា និងឯកសារចាំបាច់នានាសម្រាប់ការតាំងពិព័រណ៍ ដើម្បីធានាសុវត្ថិភាព និងលើកកម្ពស់តម្លៃវត្ថុសិល្បៈបុរាណខ្មែរ
- ពិនិត្យនិងសម្រេចលើវត្ថុសិល្បៈបុរាណខ្មែរដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស និងលើកតម្លៃធានារ៉ាប់រង
- ពិនិត្យតាមដានដំណើរការបច្ចេកទេស ការវេចខ្ចប់ ការដឹកជញ្ជូន និងការដាក់តាំងវត្ថុសិល្បៈបុរាណខ្មែរ
- បំពេញភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣.-**

សេចក្តីសម្រេចលេខ៥៥ សសរ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការអន្តរក្រសួងដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ២រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ